ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករបរធនបាលកិច្ច**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករបរធនបាលកិច្ច សូមប្រកាសគាំទ្រយ៉ាងពេញទំហឹងចំពោះប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងនាថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១ នៅខេត្តព្រះសីហនុ ដែលបានប្រកាសគាំទ្រ **ឯកឧត្តម ហ៊ុន ម៉ាណែត** ជាបេក្ខភាពនាយករដ្ឋមន្ត្រីមួយរូប នាពេលអនាគត។

**ឯកឧត្តម ហ៊ុន ម៉ាណែត** ពិតជាយុវជនឆ្នើមមួយរូប ពោរពេញដោយសមត្ថភាព និងទេពកោសល្យខ្ពស់ ព្រមទាំងមានគុណធម៌ និងសីលធម៌ដ៏ល្អក្នុងការដឹកនាំ។ កន្លងមក **ឯកឧត្តម** តែងតែទទួលបានការកោតសរសើរ ការគោរពស្រលាញ់ពីបងប្អូនប្រជាពលរដ្ឋ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធក្នុងបេសកកម្មដ៏ឧត្តុងឧត្តមក្នុងបុព្វហេតុជាតិ មាតុភូមិ និងប្រជាពលរដ្ឋ។

យើងខ្ញុំទាំងអស់គ្នាមានជំនឿយ៉ាងមុតមាំថា **ឯកឧត្តម ហ៊ុន ម៉ាណែត** ពិតជាស័ក្តិសមក្នុងមុខតំណែងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាពេលអនាគត និងបន្តវេនដឹកនាំកម្ពុជាឆ្ពោះទៅភាពរីកចម្រើនលើគ្រប់វិស័យ និងបន្តរក្សាបាននូវសន្តិភាព វិបុលភាព សេចក្តីសុខ និងសុភមង្គល ជូនប្រជាជនកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២១

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រី**
**នៃនិយ័តករបរធនបាលកិច្ច**
**អគ្គនាយក**

**សុខ ដារ៉ា**

អាសយដ្ឋាន : អគារ១៦៨F (ជាន់ទី៨) ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Address : Building 168F (8th Floor), Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia